**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៣៤៥៨ មស.ក្រ

ថ្ងៃ ចន្ទ ៦រោច ខែ ទុតិយាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**គ្រប់ក្រសួង-ស្ថាប័ន**

**កម្មវត្ថុ:** -ស្តីពីសំណើសុំពន្លឿនការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល ។

**យោង:** -ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

-លិខិតលេខ ២៤២១ មស.ត្រ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការពន្លឿនការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការស៊ីវិល ។

ខ្ញុំមានកិត្តិយស សូមគោរពជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាបថា ដើម្បីឱ្យការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិលឱ្យបានទាន់ពេលវេលា និងជាផលប្រយោជន៍ដល់មន្ត្រីរាជការ ក្រសួងមុខងារសាធារណៈ សូមជម្រាបជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមេត្តាយកចិត្តទុកដាក់អនុវត្តលើការដំឡើងឋានន្តរស័ក្តិ ថ្នាក់ជូនមន្ត្រីរាជការស៊ីវិល តាមវេនជ្រើសរើស វេនអតីតភាពការងារ និងតាមកម្រិតសញ្ញាបត្រឱ្យបានទាន់ពេលវេលា និងចូលរួមសហការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពខ្ពស់ ដូចខាងក្រោម៖

- ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ជូនមន្ត្រីរាជការស៊ីវិល ត្រូវអនុវត្តអនុលោមមាត្រា២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិជាធរមាន

- ការគិតគូរដំឡើងឋានន្តរស័ក្តិ ថ្នាក់ជូនមន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ ត្រូវគិតចំពោះមន្ត្រីរាជការស៊ីវិលដែលខិតខំបម្រើការងារពិតប្រាកដ និងមានរយៈពេលអប្បបរិមានៃការឡើងថ្នាក់ត្រូវកម្រិត២(ពីរ)ឆ្នាំគិតមកដល់ថ្ងៃទី១៣ ខែមេសា នៃឆ្នាំនីមួយៗ

- ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ គ្រប់ក្រសួង ស្ថាប័ន ត្រូវផ្តល់សំណុំឯកសារមកដល់ក្រសួងមុខងារសាធារណៈ ឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី **១៥ ខែ មករា រៀងរាល់ឆ្នាំ** ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការជូនបានទាន់ពេលវេលា

- ចំពោះមន្ត្រីរាជការស៊ីវិលដែលឡើងឋានន្តរស័ក្តិ ថ្នាក់ តាមកម្រិតសញ្ញាបត្រ ត្រូវស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់ ដោយសំអាងលើសញ្ញាបត្រពិតប្រាកដ អនុវត្តអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងត្រូវធ្វើលិខិតមកក្រសួងមុខងារសាធារណៈ **តែមួយលើកប៉ុណ្ណោះគឺក្នុងខែសីហា រៀងរាល់ឆ្នាំ**

- ដោយឡែកចំពោះករណីមន្ត្រីរាជការ**ដែលដល់អាយុចូលនិវត្តន៍នៅឆ្នាំបន្ទាប់**(ការដំឡើងឋានន្តរស័ក្តិកិត្តិយស) គ្រប់ក្រសួង ស្ថាប័ន ត្រូវលើកសំណើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់ ដូចមានចែងក្នុងមាត្រា **៣២** នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល មកក្រសួងមុខងារសាធារណៈ **យ៉ាងតិចមួយឆ្នាំមុនពេលចូលនិវត្តន៍** ដើម្បីឱ្យក្រសួងមុខងារសាធារណៈមានពេលវេលាគ្រប់គ្រាន់ក្នុងការផ្តល់ទិដ្ឋាការជូន និងធ្វើការបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ(បៀវត្ស) និងបោះពុម្ពសលាកប័ត្រចូលនិវត្តន៍ឱ្យស្របតាមឋានន្តរសក្តិ និងថ្នាក់ចុងក្រោយ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន**
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-គ្រប់រាជធានី ខេត្ត ដើម្បីសហការអនុវត្ត
-ឯកសារ-កាលប្បវត្តិ